YUNNAN DAILY PRESS GROUP
云南日报报业集团
No.133

# ប្រទេសចិន-ខេត្តយូនណាន

រស្មីឥន្ទធនូ ប្រចាំខែ

YUNNAN DAILY PRESS GROUP
english.yunnan.cn

ឆ្នាំទី 25 លេខ 7491 ថ្ងៃសុក្រ ទី24 ខែ វិច្ឆិកា ឆ្នាំ 2017


## សហគមន៍រួមវាសនាចិន-អាស៊ានផ្ដល់ផលប្រយោជន៍ជាក់ស្ដែងដល់ប្រជាជននៃបណ្ដាប្រទេសនានា

នៅថ្ងៃទី ១០ ខែវិច្ឆិកា លោក ស៊ី ជីនភីង បានអញ្ជើញចូលរួម និងថ្លែងសុន្ទរកថាក្នុងកិច្ចប្រជុំកំពូលថ្នាក់ដឹកនាំឧស្សាហកម្ម និងពាណិជ្ជកម្មនៃអង្គការសហប្រតិបត្តិការសេដ្ឋកិច្ច និងពាណិជ្ជកម្មអាស៊ី-ប៉ាស៊ីហ្វិកនៅក្រុង ដាណាង ប្រទេសវៀតណាម ។ លោកមានប្រសាសន៍ថា ភាគីចិននឹងរួមសហការគ្នាជាមួយបណ្ដាប្រទេសនានា ជំរុញឱ្យកាន់តែស៊ីជម្រៅនូវការស្ថាបនា "ខ្សែក្រវាត់មួយនិងផ្លូវមួយ " ដើម្បីចាក់បញ្ចូលនូវកម្លាំងចលករថ្មីសម្រាប់ជំរុញការអភិវឌ្ឍន៍រួមគ្នា ។ ការប្រកាន់ខ្ជាប់នូវពហុភាគីនិយម ជំរុញការរួមគ្នាពិគ្រោះពិភាក្សា ស្ថាបនា និងចែករំលែកគ្នាបង្កើតទំនាក់ទំនងភាពជាដៃគូជិតស្និទ្ធ និងបង្កើតសហគមន៍រួមវាសនាមនុស្សជាតិ គឺជានិន្នាការអភិវឌ្ឍចាំបាច់នៃការគ្រប់គ្រងសេដ្ឋកិច្ចពិភពលោកក្រោមស្ថានការណ៍ថ្មី ។

ប៉ុន្មានឆ្នាំនេះសហគ្រាសចិនបានបណ្ដាក់ទុនវិនិយោគច្រើននៅប្រទេសអាស៊ានហើយបានទទួលលទ្ធផលជាផ្លែផ្កា រួមមានគម្រោងផ្លូវដែក ហ្សាកាតា-បានឌុង គម្រោងផ្លូវដែកចិន-ឡាវ និងគម្រោងសាងសង់ហេដ្ឋារចនាសម្ព័ន្ធសំខាន់មួយចំនួនទៀតដែលបាននាំមកនូវផលប្រយោជន៍ជាក់ស្ដែងជូនដល់ប្រជាជនកាន់តែច្រើននៃបណ្ដាប្រទេសពាក់ព័ន្ធតាមបណ្ដោយ "ខ្សែក្រវាត់មួយនិងផ្លូវមួយ" ។ ក្នុងដំណើរនៃការកសាងសហគមន៍រួមវាសនាមនុស្សជាតិចិន-អាស៊ានជោគវាសនារបស់បណ្ដាប្រទេសនានាកំពុងតែបង្ហាញពីការផ្លាស់ប្ដូរយ៉ាងល្អប្រសើរ គួរឱ្យកត់សម្គាល់ ។



ក្រុមកម្មករនៅក្នុងស្រុកកំពុង តែរវល់នឹងការងារនារោងចក្រនៅ ក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ (រូបថតដោយ Yu Jiangning )

**• "ភាសាចិនធ្វើឱ្យខ្ញុំរកបានការងារល្អ"**

តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ នៃប្រទេសកម្ពុជា បានក្លាយជាតំបន់សេដ្ឋកិច្ចពិសេសដែលមានទ្រង់ទ្រាយធំជាងគេ និងផ្ដល់ឱកាសការងារច្រើនបំផុតនៅប្រទេសកម្ពុជា ។ តំបន់សេដ្ឋកិច្ចពិសេសនេះបានត្រូវគេចាត់ទុកជាគំរូនៃការធ្វើកិច្ចសហប្រតិបត្តិការ "ខ្សែក្រវាត់មួយនិងផ្លូវមួយ " រវាងប្រទេសចិននិងកម្ពុជា ។

តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុត្រូវបង្កើតដោយសហគ្រាសចិននិងកម្ពុជា ។ សព្វថ្ងៃតំបន់សេដ្ឋកិច្ចពិសេសនេះមានហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រាន់សម្រាប់ការរស់នៅ និងការធ្វើអាជីវកម្ម ហើយមានសហគ្រាសចិន អឺរ៉ុប អាមេរិក ជប៉ុន និងកូរ៉េខាងត្បូងចំនួនជាង១០០ បានចូលធ្វើអាជីវកម្មនៅទីនេះ ដែលបានផ្ដល់ឱកាសការងារដល់ប្រជាជនខ្មែរ ១,៦ ម៉ឺននាក់ ។

តំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុប្រកាន់ខ្ជាប់នូវគោលការណ៍ដែលខិតខំផ្ដល់ឱកាសការងារកាន់តែច្រើនដល់ប្រជាជននៅតាមតំបន់ ហើយបានបង្កើតមជ្ឈមណ្ឌលបណ្ដុះបណ្ដាលពិសេស ដើម្បីរៀបចំវគ្គបណ្ដុះបណ្ដាលផ្នែកភាសានិងវិជ្ជាជីវៈឱ្យប្រជាកសិករដែលបានធ្វើឱ្យពួកគេមានភាពជំនាញ និងសមត្ថភាពគ្រប់គ្រាន់សម្រាប់ធ្វើការងារឱ្យបានល្អប្រសើរ ។

កញ្ញា ឆឺន ស្រៀវលី ជាអ្នកបកប្រែម្នាក់នៃក្រុមហ៊ុនមួយក្នុងតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ។ ២ឆ្នាំ មុន គាត់បានទទួលឱកាសទៅរៀនភាសាចិននៅមជ្ឈមណ្ឌលបណ្ដុះបណ្ដាលនៃតំបន់សេដ្ឋកិច្ចពិសេសក្រុងព្រះសីហនុ ហើយបានក្លាយជាអ្នកបកប្រែដ៏ប៉ិនប្រសប់ម្នាក់តាមរយៈការខិតខំរៀនសូត្រ ។ គាត់បានប្រាប់អ្នកកាសែតដោយមានភាពសប្បាយរីករាយថា ការរៀនភាសាចិនបានធ្វើឱ្យខ្ញុំរកបានការងារល្អ ។ ឆ្នាំនេះ ខ្ញុំបានសាងសង់ផ្ទះថ្មី ហើយបានទិញគ្រឿងតុបតែង និងគ្រឿងអគ្គិសនីថ្មី។

**• "មានទឹកស្អាតប្រើប្រាស់ពិតជាល្អណាស់"**

លោក អ៊ូ ឡាជា អ្នកភូមិលើកោះម៉ាតី នៅត្រើយខាងលិចនៃប្រទេសមីយ៉ាន់ម៉ា ប្រាប់អ្នកកាសែតដោយមានភាពសប្បាយរីករាយថា កាលពីមុនខ្ញុំត្រូវទៅយកទឹកភ្លៀងនៅស្រះស្ដុកទឹក តែឥឡូវមានទឹកស្អាតប្រើប្រាស់ ពិតជាល្អណាស់ ។ យើងទាំងអស់គ្នាគាំទ្រគម្រោងនេះ ។ ពាក្យថា "គម្រោង" ដែលលោកបានលើកឡើងនោះ គឺចង្អុលសំដៅទៅលើគម្រោងសាងសង់បំពង់បញ្ជូនប្រេងកាត និងឧស្ម័នចិន-មីយ៉ាន់ម៉ា ដែលជាគម្រោងគំរូមួយស្ថិតនៅក្រោមក្របខ័ណ្ឌគំនិតផ្ដួចផ្ដើម "ខ្សែក្រវាត់មួយ និងផ្លូវមួយ" ។

កោះម៉ាតី ជាទីចាប់ផ្ដើមនៃគម្រោងសាងសង់បំពង់បញ្ជូនប្រេងកាត និងឧស្ម័នចិន-មីយ៉ាន់ម៉ានេះ ។ គម្រោងនេះបានកែប្រែទាំងស្រុងនូវការរស់នៅរបស់អ្នកស្រុកនៅក្នុងភូមិនេះ ។ កាលពីមុនកោះម៉ាតីជាកូនកោះដាច់ស្រយាលមួយដែលគ្មានផ្លូវគ្មាន ទឹកសាប និងមានកង្វះខាតសម្ភារៈតែបច្ចុប្បន្នស្ទើរគ្រប់ភូមិលើកោះនេះសុទ្ធតែបានសាងសង់ផ្លូវថ្នល់ និងមានប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត។ ជាពិសេសអ្នកភូមិមានថាមពលអគ្គិសនប្រើប្រាស់ទាំង២៤ម៉ោងហើយបានសាងសង់ស្ថានីយផ្សាយសេវាទូរស័ព្ទ3 Gសាលារៀននិងមជ្ឈមណ្ឌលសុខភាពជាដើម៕

## ពិព័រណ៍ទេសចរណ៍ឆ្នាំ២០១៧ ទាក់ទាញប្រទេស និងតំបន់ចំនួន៧១

ចាប់ពីថ្ងៃទី១៧ ដល់ទី១៩ ខែវិច្ឆិកា ពិព័រណ៍ទេសចរណ៍អន្តរជាតិចិនឆ្នាំ២០១៧ បានប្រារព្ធនៅក្រុងគុនមីងនៃខេត្តយូនណាន ។ ពិព័រណ៍នេះរៀបចំក្រោមប្រធានបទ "ខេត្តយូនណាន ដែលប្រកបដោយកម្លាំងទាក់ទាញចែករំលែកគ្នាជាមួយពិភព-លោក" ហើយបានផ្សព្វផ្សាយពីខ្លឹមសារសំខាន់ថា ខេត្តយូនណានមានរមណីយដ្ឋានតែមួយ រមណីយដ្ឋាននេះគឺមានឈ្មោះថា "យូនណាន" ។

ពិព័រណ៍ទេសចរណ៍ឆ្នាំនេះបានទាក់ទាញប្រទេស និងតំបន់ចំនួន៧១ ។ ក្រុមហ៊ុនទេសចរណ៍បរទេសចំនួន៥២៧ ដែលមកពីប្រទេសរុស្ស៊ី អាមេរិក អឺរ៉ុប ព្រមទាំងតំបន់ហុងកុង ម៉ាកាវ និងតៃវ៉ាន់របស់ប្រទេសចិនបានចូលរួមការដាក់តាំងពិព័រណ៍នេះ ។ ជាពិសេសប្រទេសចំនួនបួន រួមមានប្រទេសដាណឺម៉ាក បេឡារុស ហុងគ្រី និងហ្ស៊ីមបាវ៉េបានចូលរួមក្នុងពិព័រណ៍នេះជាលើកដំបូង ។ មន្ត្រីទេសចរណ៍នៃប្រទេសជាសមាជិកអាស៊ានទាំង១០បានចូលរួមយ៉ាងសកម្មក្នុងពិព័រណ៍នេះ ។

ពិព័រណ៍ទេសចរណ៍នេះបានបង្ហាញពីលក្ខណៈពិសេសគួរឱ្យកត់សម្គាល់ចំនួនបី គឺទី១-រៀបចំជាលើកដំបូងនូវពិធីបិទបញ្ចប់សកម្មភាព "ឆ្នាំសហប្រតិបត្តិការទេសចរណ៍អាស៊ាន" ក្នុងឱកាសពិព័រណ៍ទេសចរណ៍ ។ ទី២-រៀបចំជាលើកដំបូងនូវកិច្ចប្រជុំពិភាក្សាការងារនៃសហព័ន្ធទីក្រុងទេសចរណ៍ទន្លេឡានឆាង-មេគង្គ ។ ទី៣-រៀបចំជាលើកដំបូងនូវកម្មវិធីបង្ហាញម៉ូតសម្លៀកបំពាក់ជនជាតិភាគតិចខេត្តយូនណានក្នុងឱកាសសកម្មភាព "រាត្រីសាំងកីលីឡា" ៕ **ដោយ ឈូ តុងហួ**



នំផ្កាដ៏ធំទម្ងន់មួយពាន់តោនដែលត្រូវបានបង្ហាញនៅក្នុងអំឡុងពិព័រណ៍ទេសចរណ៍អន្តរ-ជាតិចិនដោយមានវិជ្ឈមាត្រ៣,៤៥ម៉ែត្រធ្វើពី ម្សៅស្រូវសាឡីទម្ងន់៦០០គីឡូក្រាម និង ផ្កា ទម្ងន់៤០០គីឡូក្រាម (រូបថតដោយ Yang Zheng )

## ការប្រកួតម៉ារ៉ាតុងក្រុងគុនមីងនៃអង្គការសហប្រតិបត្តិការសៀងហៃចាប់ផ្ដើមចុះឈ្មោះ

ការប្រកួតរត់ម៉ារ៉ាតុងក្រុងគុនមីងនៃអង្គការសហប្រតិបត្តិការសៀងហៃ (SCO) ឆ្នាំ២០១៧ នឹងបើកការប្រកួតនៅថ្ងៃទី៣១ ខែធ្នូ តាមមាត់បឹងទានឈឺក្នុងក្រុងគុនមីង ។

ការប្រកួតនេះរៀបចំក្រោមប្រធានបទ "រត់ក្នុងទីក្រុងនិទាឃរដូវដោយមានភាពសប្បាយរីករាយកាន់តែរាប់អានគ្នា កាន់តែជិតស្និទ្ធ កាន់តែមានភាពចុះសម្រុងគ្នា" និង "រត់បានផលកាន់តែល្អសម្រេចសុបិននៅខេត្តយូនណានដ៏ចម្រុះពណ៌" ។ ការប្រកួតនេះបែងចែកជាការប្រកួតបួនប្រភេទ គឺការរត់ប្រណាំងម៉ារ៉ាតុង ពាក់កណ្ដាលម៉ារ៉ាតុង រត់ចម្ងាយ៥គីឡូម៉ែត្រ រត់ចម្ងាយ២ គីឡូម៉ែត្រ (សម្រាប់កូននិងឪពុកម្ដាយ) សរុបមាន១,៦ម៉ឺននាក់នឹងចូលរួមក្នុងការប្រកួតនេះ ។

អ្នកដែលមានបំណងចង់ចូលរួមក្នុងការប្រកួតនេះអាចចុះឈ្មោះតាមវេបសាយ http://www.sco-marathon.com ក្នុងអំឡុងពេលពីថ្ងៃទី១៥ ខែវិច្ឆិកា ដល់ថ្ងៃទី១០ ខែធ្នូ ។ បន្ទាប់ពីនោះ គណៈកម្មការរៀបចំការប្រកួតនឹងរៀបចំពិធីចាប់ឆ្នោតដើម្បីកំណត់បញ្ជីឈ្មោះនៃកីឡាករកីឡាការិនីដែលអាចចូលរួមក្នុងការប្រកួតនេះ ៕ **ដោយ ហ៊ឹង យ៉ុងស៊ីង**

## ភារកិច្ចជាប្រវត្តិសាស្ត្រស្នាក់ទីទំនួលខុសត្រូវរបស់ប្រទេសចិន

អ្នករៀបរៀង: សមាជបក្សកុម្មុយនិស្តចិន បានទទួលការចាប់អារម្មណ៍កម្រិតខ្ពស់ពីបណ្ដាប្រទេសនានាលើពិភពលោក ។ ពេលនេះ យើងខ្ញុំសូមបន្តបកស្រាយអំពី "ពាក្យគន្លឹះ នៃសមាជបក្សកុម្មុយនិស្តចិនលើកទី១៩" ដើម្បីធ្វើឱ្យលោកអ្នកមានការយល់ដឹងកាន់តែស៊ីជម្រៅអំពីសមាជបក្សកុម្មុយនិស្តចិនលើកទី ១៩ ។

ពាក្យគន្លឹះនៃសមាជបក្សកុម្មុយនិស្តចិនលើកទី ១៩ បានបង្កប់នូវខ្លឹមសារសំខាន់មួយចំនួនធំរួមមានភារកិច្ចជាប្រវត្តិសាស្ត្រក្នុងយុគសម័យថ្មីរបស់គណបក្សកុម្មុយនិស្តចិន ការសម្រេចគោលដៅ "មួយរយឆ្នាំ" ទី ១ និងការដើរឆ្ពោះទៅកាន់គោលដៅ "មួយរយឆ្នាំ" ទី ២ ជាដើម ។

**• "ចំណុចអស្ចារ្យទាំង ៥"**

គោលដៅនៃការស្ដារប្រជាជាតិចិនឱ្យមានភាពរុងរឿងឡើងវិញជាសុបិនអស្ចារ្យបំផុតរបស់ជនជាតិចិនក្នុងសម័យទំនើប ។ ដើម្បីសម្រេចបានសុបិនដ៏អស្ចារ្យនេះ យើងត្រូវធ្វើយុទ្ធនាការដ៏អស្ចារ្យ អនុវត្តន៍វិស្វកម្មដ៏អស្ចារ្យ និងជំរុញការអភិវឌ្ឍបុព្វហេតុដ៏អស្ចារ្យ ។ "ចំណុចអស្ចារ្យទាំង ៥" នេះតភ្ជាប់គ្នាយ៉ាងរឹងមាំ និងមានទំនាក់ទំនងជិតស្និទ្ធ ហើយអាចបំពេញបន្ថែមគ្នាទៅវិញទៅមក ។

**• "ដំណាក់កាលឆ្លងកាត់ ជាប្រវត្តិសាស្ត្រ"**

រយៈពេលពីសមាជបក្សកុម្មុយនិស្តចិនលើកទី១៩ដល់ទី២០ គឺជាដំណាក់កាលឆ្លងកាត់ដែលមានលក្ខណៈជាប្រវត្តិសាស្ត្ររបស់គោលដៅ "មួយរយឆ្នាំ" ទាំង២ ។ យើងមិនគ្រាន់តែត្រូវបង្កើតសង្គមធូរធារគ្រប់ជ្រុងជ្រោយ និងសម្រេចបាននូវគោលដៅ "មួយរយឆ្នាំ" ទី១ ប៉ុណ្ណោះទេ ហើយត្រូវបោះជំហានថ្មីសំដៅកសាងប្រទេសសង្គមនិយមទំនើបភាវូបនីយកម្មគ្រប់ជ្រុងជ្រោយ និងដើរឆ្ពោះទៅកាន់គោលដៅ "មួយរយឆ្នាំ" ទី ២ ។

**• "ដំណាក់កាល ២"**

សមាជបក្សកុម្មុយនីស្តចិនបានបែងចែកដំណើរសាងសង់ប្រទេសសង្គមនិយមទំនើបភាវូបនីយកម្ម គ្រប់ជ្រុងជ្រោយទៅជាដំណាក់កាល២ ។ ដំណាក់កាលទី១ គឺសម្រេចជាមូលដ្ឋាននូវទំនើបភាវូបនីយកម្មសង្គមនិយម ពីឆ្នាំ២០២០ ដល់ឆ្នាំ២០៣៥ ។ ដំណាក់កាលទី២ គឺបង្កើតដោយជោគជ័យនូវប្រទេសសង្គមនិយមទំនើបភាវូបនីយកម្មដ៏ខ្លាំងក្លា ដែលមានភាពធូរធារប្រជាធិបតេយ្យ អរិយធម៌ និងសម្រស់ស្អាតពីឆ្នាំ២០៣៥ដល់ពាក់កណ្ដាលសតវត្សរ៍នេះ ៕

***(បកសម្រួលពីកាសែតប្រជាជនដេលីបោះពុម្ពផ្សាយនៅឯនាយសមុទ្រ)***

## ខេត្តយូនណានដាក់តាំងបង្ហាញលទ្ធផលនៃការសិក្សាស្រាវជ្រាវថ្មីក្នុងពិព័រណ៍បច្ចេកទេសថ្មី និងកម្រិតខ្ពស់អន្តរជាតិចិន



(រូបថតដោយ លី ជួនយុន)

ពេលថ្មីៗនេះ ពិព័រណ៍បច្ចេកទេសថ្មី និងកម្រិតខ្ពស់អន្តរជាតិចិនលើកទី១៩ បានបើកពិព័រណ៍នៅមជ្ឈមណ្ឌលសន្និសីទ និងពិព័រណ៍អន្តរជាតិក្រុងសិនជិន ។ ក្នុងឱកាស ពិព័រណ៍នេះ ខេត្តយូនណានបានផ្សព្វផ្សាយដោយផ្ដោតសំខាន់ទៅលើគម្រោងផលិតកម្មឱសថជីវសាស្ត្រ និងគម្រោងថែរក្សាសុខភាពហើយបានរៀបចំលទ្ធផលសិក្សាស្រាវជ្រាវចំនួន៤៨មុខ និងគម្រោងសំខាន់ចំនួន៥២គម្រោងឱ្យចូលរួមការតាំងពិព័រណ៍ដែលគ្របដណ្ដប់លើវិស័យសំខាន់ចំនួន ប្រាំមួយ រួមមានសម្ភារៈថ្មី គ្រឿងបរិក្ខារជឿនលឿន ព័ត៌មានវិទ្យា កសិកម្មពិសេសលើខ្ពង់រាប ការថែរក្សាបរិស្ថាន និងសំចៃថាមពលជាដើម ។ គម្រោងវេទិកាសុខាភិបាលដែលមានលក្ខណៈវៃឆ្លាតបច្ចេកទេសឈានមុខអំពីលោហធាតុជាវត្ថុធាតុ និងម៉ាស៊ីនជំរុញសម្រាប់អ្នកមុជទឹកជាគម្រោង និងផលិតផលពិសេស ដែលត្រូវដាក់តាំងបង្ហាញ ក្នុងពន្លាពិព័រណ៍ខេត្តយូនណាន ៕

**ដោយ លី ជួនយុន**

## ចិន និងកម្ពុជាពង្រឹងកិច្ចសហប្រតិបត្តិការលើការបណ្ដុះបណ្ដាលវិជ្ជាជីវៈ

កាលពីពេលថ្មីៗនេះ វិទ្យាស្ថានបច្ចេកទេសឧស្សាហកម្មនៃប្រទេសកម្ពុជា និងវិទ្យាស្ថានបណ្ដុះបណ្ដាលវិជ្ជាជីវៈក្រុងហ្ស៊ីប៉ូខេត្តសានតុងប្រទេសចិន បានចុះហត្ថលេខាលើអនុស្សរណៈយោគយល់ស្ដីពីកិច្ចសហប្រតិបត្តិការ ដើម្បីបង្កើនការផ្លាស់ប្ដូរ និងកិច្ចសហប្រតិបត្តិការលើវិស័យបណ្ដុះបណ្ដាលវិជ្ជាជីវៈរវាងភាគីទាំងពីរ ។

ក្រោមក្របខ័ណ្ឌអនុស្សរណៈយោគយល់នេះ សិស្សកម្ពុជានឹងអាចមានឱកាសទទួលអាហារូបករណ៍ និងទៅបន្តការសិក្សានៅប្រទេសចិន ។ វិទ្យាស្ថានទាំងពីរមានផែនការរួមគ្នាបង្កើតកម្មវិធីសិក្សា និងផ្ដល់សញ្ញាបត្របញ្ជាក់ការសិក្សាសាលាពីរ ហើយទទួលស្គាល់ពិន្ទុសិក្សាទៅវិញទៅមក ។ ជាពិសេស ភាគីទាំងពីរនឹងពិគ្រោះពិភាក្សាអំពីការបង្កើតមជ្ឈមណ្ឌលបណ្ដុះបណ្ដាល ដើម្បីរៀបចំវគ្គបណ្ដុះ-បណ្ដាលវិជ្ជាជីវៈសម្រាប់បំពេញតម្រូវការរបស់សហគ្រាសចិនដែលធ្វើវិនិយោគនៅប្រទេសកម្ពុជា ៕

**ដោយ ម៉ាវ ភីងហ្វី (ស៊ុនហួ ចិន)**